**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៥៤៤៧ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## បញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

### ប្រការ ១.-

រាល់ទំនិញនាំចេញ ឬនាំចូលទោះជាជាប់ពន្ធ និងអាករក្តី ឬត្រូវបានលើកលែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ ។



អគារលេខ ៩២ វិថីវត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.



ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប្រតិវេទន៍គយគឺជាឯកសាររដ្ឋបាលតែមួយ (Single Administrative Document –SAD) ដែលមានកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ទម្រង់ប្រតិវេទន៍គយផ្សេងទៀតសម្រាប់តម្រូវការនៃការនាំចេញ នាំចូលរបស់អ្នកដំណើរ កញ្ចប់ប្រៃសណីយ៍ និងគោលបំណងផ្សេងទៀតតាមការចាំបាច់ ។

ប្រតិវេទន៍គយ ដែលត្រូវបានចុះបញ្ជិកាដោយគយ គឺជាឯកសារត្រឹមត្រូវតាមច្បាប់តែមួយគត់ ដែលអាចត្រូវបានយកទៅប្រើប្រាស់ ដើម្បីជូនជាសំអាងថាទំនិញនោះត្រូវបាននាំចូលមកក្នុង ឬត្រូវបាននាំចេញពីកម្ពុជា ។

**ប្រការ ២.-**

ប្រតិវេទន៍គយ ត្រូវដាក់នៅការិយាល័យគយមានការអនុញ្ញាត ដែលកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ។

ប្រតិវេទន៍គយ អាចត្រូវបានដាក់នៅការិយាល័យគយ មុនពេលការមកដល់នៃទំនិញប្រសិនបើមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

ចំពោះការនាំចូល:

ក. នៅពេលដែលទំនិញមិនត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំព្រួញ ប្រតិវេទន៍គយត្រូវដាក់នៅការិយាល័យគយនាពេលដែលទំនិញមកដល់ វៀរលែងតែមានការអនុញ្ញាតឲ្យដាក់ប្រតិវេទន៍មុនពេលទំនិញមកដល់ ស្របតាមកថាខ័ណ្ឌ២ នៃប្រការនេះ ។ ប្រសិនបើទំនិញមកដល់មុនពេលចាប់ផ្ដើមប្រតិបត្តិការរបស់ការិយាល័យគយ ប្រតិវេទន៍គយត្រូវតែដាក់ភ្លាមនៅពេលចូលធ្វើការ ។

ខ. ក្នុងករណីដែលទំនិញត្រូវបានរាយការណ៍ដល់គយនៅលើប្រតិវេទន៍បំព្រួញ ប្រតិវេទន៍គយត្រូវតែដាក់នៅការិយាល័យគយក្នុងរយៈពេលបី (៣) ថ្ងៃគត់ បន្ទាប់ពីទំនិញមកដល់ វៀរលែងតែទំនិញនោះត្រូវបានដាក់បញ្ចូលក្នុងសន្និធិគយបណ្ដោះអាសន្ន ឬត្រូវបានដាក់ក្រោមនីតិវិធីឆ្លងកាត់ ។

ចំពោះការនាំចេញ ប្រតិវេទន៍គយត្រូវដាក់ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌ ក កថាខ័ណ្ឌ ៣ នៃប្រការនេះ ដោយរាប់បញ្ចូលទាំងការដាក់ប្រតិវេទន៍គយមុនពេលទំនិញមកដល់ ។

**ប្រការ ៣.-**

ទំនិញនាំចេញ ឬនាំចូល ត្រូវប្រកាសដោយម្ចាស់ទំនិញ ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

បុគ្គលដែលបានទទួលការអនុញ្ញាតឲ្យបំពេញបែបបទគយ រួមមាន ៖

- បុគ្គលដែលបានទទួលកាអនុញ្ញាតជាជើងសារគយ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសារគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់អាជីវកម្មរបស់ខ្លួន ។ បុគ្គលនេះ អាចទទួលបានការអនុញ្ញាតឲ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកដទៃបាន សម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួនជាបណ្តោះអាសន្ន ប្រសិនបើមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ប្រតិវេទន៍គយ ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ឬ តាមមធ្យោបាយអេឡិចត្រូនិក។ បញ្ញត្តិ និងលក្ខខណ្ឌ សម្រាប់ការដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធតាមមធ្យោបាយអេឡិចត្រូនិកមានចែងក្នុងឧបសម្ព័ន្ធ ខ នៃប្រកាសនេះ ។

សម្រាប់គោលបំណងនៃការអនុវត្តច្បាប់ និងបទបញ្ញត្តិគយជាធរមាន និងសម្រាប់គោលបំណងស្ថិតិ ប្រតិវេទន៍គយ ត្រូវមានចុះរាល់សូចនាចាំបាច់ស្របតាមការកំណត់ពន្យល់ដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃប្រកាសនេះ និងបណ្តាសេចក្តីណែនាំដែលចេញដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

ឯកសារភ្ជាប់ជាមួយប្រតិវេទន៍គយ រួមមាន ៖ វិក្កយប័ត្រទំនិញ បញ្ជីវេចខ្ចប់ និងឯកសារដឹកជញ្ជូន ។ ក្នុងករណីចាំបាច់ និវេទន៍ប័ណ្ណ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនប័ត្រដើមកំណើត វិញ្ញាបនប័ត្រធានារ៉ាប់រង និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវភ្ជាប់ជាមួយប្រតិវេទន៍គយ ។

ក្នុងករណីខ្លះ នាយកទីចាត់ការគយ និងរដ្ឋាករ អាចសម្រេចអនុញ្ញាតឲ្យប្រកាសដោយផ្ទាល់មាត់ជំនួសការប្រកាសជាលាយល័ក្ខអក្សរ ។

ប្រតិវេទន៍គយត្រូវតែមានចុះហត្ថលេខាដោយប្រតិវេទករ ។

**ប្រការ ៥.-**

កាលបើទំនិញច្រើនមុខ ត្រូវបានបំពេញក្នុងប្រតិវេទន៍គយតែមួយមុខទំនិញនីមួយៗ ត្រូវបានចាត់ទុកជាកម្មវត្ថុនៃការប្រកាសដោយឡែក ។ មុខទំនិញ នីមួយៗត្រូវតែចុះដោយឡែកពីគ្នា និងត្រូវចុះលេខសំគាល់ចំណាត់ថ្នាក់ទំនិញឲ្យបានត្រឹមត្រូវតាមតារាងពន្ធគយជាធរមាន ។

**ប្រការ ៦.-**

កាលបើបុគ្គលមាននីតិសម្បទាធ្វើប្រតិវេទន៍គយ មិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់បំពេញប្រតិវេទន៍គយ បុគ្គលនោះអាចត្រូវបានអនុញ្ញាតឲ្យពិនិត្យទំនិញនិងដកទំនិញគំរូមុនពេលបំពេញប្រតិវេទន៍គយ ។ បុគ្គលនោះត្រូវដាក់ប្រតិវេទន៍បណ្តោះអាសន្នជូនគយ ដែលទោះជាក្នុងករណីណាក៏ដោយបុគ្គលនោះមិនអាចរួចផុតពីកាតព្វកិច្ចបំពេញប្រតិវេទន៍គយដែរ ។

ត្រូវហាមឃាត់ដល់រាល់សហត្ថកម្ម ដែលអាចបណ្តាលឲ្យប្រែប្រួលសភាពដើម ឬលក្ខណៈនៃទំនិញដែលជាកម្មវត្ថុនៃការបំពេញប្រតិវេទន៍បណ្តោះអាសន្ន ។

ទម្រង់ប្រតិវេទន៍បណ្តោះអាសន្ន និងលក្ខខណ្ឌនៃការត្រួតពិនិត្យទំនិញមុនពេលបំពេញប្រតិវេទន៍គយត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៧.-**

ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់ ព្រមទាំងមានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានានឹងត្រូវទទួលយកបាន និង ចុះបញ្ជិកាភ្លាមដោយគយ ។

ត្រូវចាត់ទុកថា ជាប្រតិវេទន៍គយដែលមិនអាចទទួលយកបាន និងមិនត្រូវ

បានចុះបញ្ជិកាដោយគយ បណ្ដាប្រតិវេទន៍ដែលខុសទម្រង់ ដែលបំពេញមិនបានត្រឹមត្រូវ និងគ្រប់គ្រាន់ ឬមិនបានភ្ជាប់ជាមួយនូវឯកសារចាំបាច់នានា ។ នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវកំណត់នូវលក្ខខណ្ឌនៃការទទួលយកបាននៃប្រតិវេទន៍គយ ។

**ប្រការ ៨.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ ប្រតិវេទករ អាចធ្វើការកែតម្រូវប្រតិវេទន៍គយ តែនៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍ និងមុនពេលចាប់ផ្តើមត្រួតពិនិត្យទំនិញជារូបវ័ន្តប៉ុណ្ណោះ ។ ការកែតម្រូវព័ត៌មានអំពី បរិមាណ និងតម្លៃ និងការតម្រូវដែលធ្វើឡើងក្រោយថ្ងៃចុះបញ្ជិកាប្រតិវេទន៍ តម្រូវឲ្យមានការអនុញ្ញាតជាមុនពីទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ៩.-**

ក្រោយពេលចុះបញ្ជិកាប្រតិវេទន៍គយ និងមុនពេលត្រួតពិនិត្យទំនិញជារូបវ័ន្ត មន្ត្រីគយត្រូវត្រួតពិនិត្យប្រតិវេទន៍គយដើម្បីផ្ទៀងផ្ទាត់ពីភាពគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃព័ត៌មានដែលបានប្រកាសលើប្រតិវេទន៍គយ រួមមាន ដើមកំណើត ចំណាត់ថ្នាក់ទំនិញ តម្លៃគិតពន្ធគយ របបគយ និងចំនួនប្រាក់ពន្ធ និងអាករដែលត្រូវបង់ ។ មន្ត្រីគយត្រូវតែពិនិត្យផងដែរនូវតម្រូវការចាំបាច់នានា ប្រសិនបើទំនិញនោះជាប្រភេទត្រូវបានហាមឃាត់ ឬជាប់កម្រិតកំណត់ ។

**ប្រការ ១០.-**

ការកែតម្រូវ ការបន្ថែម ការលុប ការបែងចែក និងការគ្រប់គ្រង សុពលភាព និងបណ្ដាតម្រូវការផ្សេងទៀតនៃប្រតិវេទន៍ និងបណ្ដាឯកសារគយត្រូវធ្វើឡើងតាមទម្រង់ និងរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ១១.-**

បន្ទាប់ពីបានត្រួតពិនិត្យឯកសារប្រតិវេទន៍គយ មន្ត្រីគយអាចធ្វើការត្រួត

ពិនិត្យជារូបវ័ន្តទាំងស្រុង ឬភាគខ្លះនៃទំនិញដែលបានប្រកាស ប្រសិនបើយល់ថាជាការចាំបាច់ដោយផ្អែកលើការវាយតម្លៃហានិភ័យ ។

ក្នុងករណីដែលមន្ត្រីគយមិនបានធ្វើការត្រួតពិនិត្យជារូបវ័ន្តលើទំនិញ ពន្ធនិងអាករ និងនីតិវិធីគយផ្សេងទៀតត្រូវអនុវត្តផ្អែកលើសេចក្តីបរិយាយ និងព័ត៌មាននានានៅលើប្រតិវេទន៍គយ និងឯកសារភ្ជាប់ ។

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយក ទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១៣
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ «ក»

## I. កំណត់ពន្យល់ប្រតិវេទន៍គយនាំចូល (ឯកសាររដ្ឋបាលតែមួយ)

ឯកសាររដ្ឋបាលតែមួយ (SAD) គឺជាឯកសារតែមួយប្រើសម្រាប់គ្រប់របបបញ្ចេញទំនិញពីគយ ការនាំចូល ការនាំចេញ ភណ្ឌាគារគយ ។ល។ ផ្នែកនេះបង្ហាញលំអិតអំពីរបៀបបំពេញ SAD សំរាប់ប្រតិវេទន៍គយនាំចូល ។ ប្រតិវេទន៍គយនាំចូលរួមមាន:

- ការនាំចូលស្ថាពរ (ដោយផ្ទាល់) / ការនាំចូលដើម្បីប្រើប្រាស់ក្នុងស្រុក - IM4
- ការនាំចូលបណ្តោះអាសន្ន - IM5
- ការនាំចូលមកវិញ - IM6
- ការនាំចូលក្នុងភណ្ឌាគារគយ - IM7
- ឆ្លងកាត់ - IM8
- តំបន់រួចពន្ធ / តំបន់សេដ្ឋកិច្ចពិសេស - IM9

ប្រអប់និមួយៗនៃ SAD ត្រូវបានរៀបចំឡើង ដែលជាការបញ្ចូលចាំបាច់ (វាត្រូវតែបំពេញ) បញ្ចូលដោយជ្រើសរើស(បំពេញប្រសិនបើមានពាក់ព័ន្ធ) ឬក្នុងករណីខ្លះប្រអប់អាចមិនចាំបាច់បំពេញ(មិនត្រូវការប្រើប្រាស់)។

ផ្នែកខាងក្រោមនេះ រៀបរាប់លំអិតពីគោលបំណងនៃប្រអប់និមួយៗនៃ SAD នៅពេលអនុវត្តប្រតិវេទន៍គយនាំចូល។ ប្រអប់និមួយៗត្រូវបានបរិយាយពីលំដាប់នៃការបញ្ចូលព័ត៌មាន ថាតើវាជាប្រអប់ចាំបាច់ ឬជាប្រអប់ជម្រើស។ ប្រអប់ខ្លះ តម្រូវឱ្យបញ្ចូលលេខកូដយោង ឬឈ្មោះតំណាងអោយព័ត៌មានយោងតាមស្តង់ដារ។ កូដយោងប្រើក្នុងកំណត់ពន្យល់នេះនឹងចេញដោយទីចាត់ការគយ និងរដ្ឋាករ។

**ការពន្យល់នៃប្រអប់ SAD សំរាប់ប្រតិវេទន៍នាំចូល**

| លេខប្រអប់ | ស្លាកសញ្ញាប្រអប់ | សកម្មភាព | បរិយាយ និង / ឬ ការប្រើប្រាស់ |
|---|---|---|---|
| 1 | ប្រភេទប្រតិវេទន៍ | ចាំបាច់ | ដើម្បីកំណត់ថាតើប្រតិវេទន៍ទំនិញត្រូវបានដាក់សំរាប់ការនាំចូល ការនាំចេញ ឬ ក៏ជាការឆ្លងកាត់គយ។<br>លេខគំរូប្រតិវេទន៍ត្រូវបានដាក់បញ្ចូលលើទម្រង់ SAD ក្នុងប្រអប់នេះ។<br>សំរាប់ប្រតិវេទន៍នាំចូលទាំងអស់ គំរូនេះគឺ "IM" ជាមួយនឹងលេខ ដើម្បីកំណត់ថាតើរបបមួយណាជាការនាំចូល ឧទាហរណ៍លេខ ៤ សំរាប់ (នាំចូលប្រើប្រាស់ក្នុងស្រុក) លេខ ៧ សំរាប់ (ស្តុកក្នុងឃ្លាំង)។ល។ |
| A: | **ការិយាល័យដាក់ប្រតិវេទន៍:** ការិយាល័យគយដែលប្រតិវេទន៍ត្រូវបានដាក់ជូនមន្ត្រីគយពិនិត្យ | | |
| | កូដការិយាល័យ | ចាំបាច់ | កូដនិងឈ្មោះការិយាល័យគយដែលប្រតិវេទន៍ (SAD) ត្រូវបានដាក់និងដំណើរការ។<br>ការិយាល័យគយដែល SAD ត្រូវបានដាក់អាចផ្សេងពីការិយាល័យគយដែលទំនិញត្រូវបាននាំចូល/នាំចេញពីប្រទេស (ប្រអប់លេខ២៩)។<br>នៅពេលប្រើប្រព័ន្ធអាស៊ីគូដា នឹងបង្ហាញដោយស្វ័យប្រវត្តិនូវឈ្មោះ |

<table>
<tr><td></td><td></td><td></td><td>ការិយាល័យ បន្ទាប់ពីកូដត្រូវបានដាក់បញ្ចូល។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបំពេញទាំងកូដការិយាល័យ និងឈ្មោះ ផ្អែកតាមបញ្ជីកូដយោង។</td></tr>
<tr><td></td><td>និវេទនប័ណ្ណ</td><td>ជម្រើស</td><td>នៅពេលនិវេទនប័ណ្ណត្រូវបានចុះបញ្ជីក្នុងអាស៊ីគូដា ប្រព័ន្ធផ្តល់នូវលេខចុះបញ្ជី។ នៅពេលអនុវត្តនិវេទនប័ណ្ណ លេខនេះនឹងត្រូវបានបញ្ចូលទៅក្នុង SAD ក្នុងប្រអប់នេះ។ ប្រតិវេទករត្រូវចុះ នូវលេខនិវេទនប័ណ្ណ ដែលផ្តល់ដោយអ្នកនាំចូល។</td></tr>
<tr><td></td><td>លេខ និងកាលបរិច្ឆេទបញ្ជិការប្រតិវេទន៍គយ</td><td>ចាំបាច់</td><td>នៅពេលប្រើប្រព័ន្ធអាស៊ីគូដា នៅកន្លែងចុះបញ្ជិកា (ការទទួលយកតាមច្បាប់ដោយគយ នៅពេលដែលទំនិញបានមកដល់ និងនៅពេលដែលចាប់ផ្តើមបំពេញឯកសារ និងការដាក់បញ្ចូលទិន្នន័យ ត្រូវបានបំពេញ)។ ប្រព័ន្ធផ្តល់លេខចុះបញ្ជីឯកភាពដោយស្វ័យប្រវត្តិតែមួយផ្សំឡើងដោយ លំដាប់អក្សរ + លេខ + កាលបរិច្ឆេទសំរាប់ការិយាល័យគយបច្ចុប្បន្ន និងឆ្នាំបច្ចុប្បន្ន។<br><br>ឧទាហរណ៍<br><br>
<table>
<tr><th>លំដាប់អក្សរ</th><th>លេខ</th><th>កាលបរិច្ឆេទ</th><th>ការិយាល័យគយ</th><th>ឆ្នាំបច្ចុប្បន្ន</th></tr>
<tr><td>I</td><td>32</td><td>15/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>I</td><td>33</td><td>20/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>I</td><td>33</td><td>20/11/2006</td><td>អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ</td><td>2006</td></tr>
</table>
<br>ការប្រើប្រាស់ SAD ដោយដៃ គយជាអ្នកផ្តល់នូវលេខចុះបញ្ជីឯកភាព (ទម្រង់ដូចគ្នាទៅនឹងទម្រង់បានផ្តល់ដោយប្រព័ន្ធ) នៅពេលដាក់ប្រតិវេទន៍គយ SAD ។ គយត្រូវគ្រប់គ្រងប្រព័ន្ធចុះបញ្ជិកា ទៅក្នុងសៀវភៅចុះបញ្ជិកា / សៀវភៅចុះលេខប្រតិវេទន៍នៅថ្នាក់ការិយាល័យគយ និងផ្អែកលើមូលដ្ឋានប្រចាំឆ្នាំ។</td></tr>
<tr><td>2</td><td>កូដអ្នកនាំចេញ / អ្នកផ្ញើទំនិញ</td><td>ជម្រើស</td><td>ប្រអប់នេះជាធម្មតា គឺជាឈ្មោះបុគ្គល ឬ ក្រុមហ៊ុន ឬ ស្ថាប័ននៅក្រៅប្រទេស (នៅក្រៅកម្ពុជា) ដែលអ្នកនាំចូលទិញទំនិញ ។<br><br>ចំពោះប្រតិវេទន៍នាំចូល ប្រអប់នេះគឺជាជំរើស ។ ប្រសិនបើមានព័ត៌មានសូមផ្តល់នូវឈ្មោះពេញ និងអាសយដ្ឋាន រួមទាំងរាសយដ្ឋានអ៊ីមេលផង (ប្រសិនបើមាន) របស់អ្នកនាំចេញ/ អ្នកផ្ញើ (អ្នកផ្គត់ផ្គង់) ទំនិញ នៅក្រៅប្រទេស។</td></tr>
<tr><td>3</td><td>ទម្រង់</td><td>ចាំបាច់</td><td>ប្រអប់នេះបង្ហាញចំនួនសរុបនៃទំព័រក្នុងប្រតិវេទន៍ ដែលរាប់បញ្ចូលទាំងទំព័រមុខ និងទំព័របន្តណាមួយ (ទំព័របន្ថែម) មានន័យថា ២, ៣ ។ល។ ទៅតាមត្រូវការ។<br><br>ដូចក្នុងឧទាហរណ៍ ប្រព័ន្ធអាស៊ីគូដានឹងបង្ហាញដោយស្វ័យប្រវត្តិ ប្រសិនបើប្រតិវេទន៍មាន៣ទំព័រ ១/៣ លើទំព័រទី១ ២/៣លើទំព័រទី ២ និង ៣/៣</td></tr>
</table>

| | | | |
|---|---|---|---|
| | | | លើទំព័រចុងក្រោយ ។<br>ការបញ្ចូល SAD ដោយដៃត្រូវអនុវត្តតាមទម្រង់ដូចគ្នា។ |
| 4 | | មិនតម្រូវ | ចំនួនបញ្ជីផ្ទុកទំនិញឬឯកសារភ្ជាប់ប្រហាក់ប្រហែលផ្សេងទៀតភ្ជាប់ជាមួយការប្រកាសទំនិញ។<br>មិនទាន់ត្រូវការ នាពេលបច្ចុប្បន្ននេះទេ។ |
| 5 | មុខទំនិញ | ចាំបាច់ | ប្រអប់នេះបង្ហាញចំនួនមុខទំនិញសរុបក្នុងប្រតិវេទន៍។ ប្រតិវេទន៍នីមួយៗអាចបំពេញមុខទំនិញបានជាអតិបរិមារហូតដល់ ៩៩មុខទំនិញ។<br>ការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា ចំនួនមុខទំនិញនឹងត្រូវបង្ហាញដោយស្វ័យប្រវត្តិ ។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបញ្ចូលក្នុងប្រអប់នេះ |
| 6 | កញ្ចប់សរុប | ចាំបាច់ | ការប្រើប្រាស់ SAD ដោយដៃ និងដោយអេឡិចត្រូនិក ប្រតិវេទករ ត្រូវបង្ហាញនូវចំនួនសរុបកញ្ចប់ សំរាប់ប្រតិវេទន៍ទាំងមូល (មានន័យថាចំនួនសរុបកញ្ចប់នៃមុខទំនិញទាំងអស់)។<br>ចំពោះទំនិញចាក់ធាលោកអ្នកអាចបញ្ចូលលេខ១ ។ |
| 7 | លេខយោង<br>ប្រតិវេទករ | ចាំបាច់ | នេះជាលេខលំដាប់ខាងក្នុង (មានន័យថាលេខប្រតិបត្តិការ) ដែលប្រតិវេទករម្នាក់ៗត្រូវបំពេញលើ SAD (ដោយដៃ ឬដោយអេឡិកត្រូនិក)។<br>ប្រតិវេទករ ត្រូវថែរក្សាផ្ទៃក្នុង "លេខប្រតិបត្តិការ" សៀវភៅចុះបញ្ជីរបស់ខ្លួន។ |
| 8 | អ្នកនាំចូល / អ្នកទទួលទំនិញ | ចាំបាច់ | ចំពោះប្រតិវេទន៍នាំចូល អ្នកទទួលទំនិញជាទូទៅជាអ្នកនាំចូលនៅក្នុងកម្ពុជា ។ អ្នកទទួលទំនិញ គឺជាបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការ ដែលទំនិញត្រូវបានគេផ្ញើអោយ។<br>ប្រតិវេទករត្រូវបំពេញ (លេខអត្តសញ្ញាណពន្ធ/អាករលើតម្លៃបន្ថែម អ.ត.ប) របស់អ្នកទទួលទំនិញ ទៅក្នុងប្រអប់កូដ។ នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ ឈ្មោះនិងអាសយដ្ឋានពេញរបស់អ្នកនាំចូល/អ្នកទទួលទំនិញ ត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើ SAD ភ្លាមនៅពេលលេខ អ.ត.ប ត្រូវបានបញ្ចូល ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទករត្រូវបំពេញ ឈ្មោះ និងអាសយដ្ឋានអ្នកនាំចូល/អ្នកទទួលទំនិញ ផ្អែកតាមបញ្ជីយោងកូដដែលបានផ្តល់ឲ្យ។<br>លេខ អ.ត.ប. ត្រូវបានផ្តល់ឲ្យដោយនាយកដ្ឋានពន្ធដារ ។<br><u>កំណត់សំគាល់:</u><br>អ្នកនាំចូល ដែលគ្មានលេខ អ.ត.ប (អ្នកនាំចូល/អ្នកទទួលទំនិញម្តងម្កាលប៉ុណ្ណោះ) ត្រូវប្រើកូដ ៩៩៩៩៩៩៩៩៩ អ្នកនាំចូល/អ្នកទទួលទំនិញម្តងម្កាល និងត្រូវបញ្ចូលឈ្មោះ លេខអត្តសញ្ញាណ ប័ណ្ណ និងអាសយដ្ឋានក្នុងប្រអប់លេខ ៩ ។ |

| | | | |
|---|---|---|---|
| | | | ចំពោះអ្នកដែលកំពុងរង់ចាំលេខ អ.ត.ប របស់ខ្លួន ឯកសារពីនាយកដ្ឋានពន្ធដារ (រាប់បញ្ចូលលេខ អ.ត.ប បណ្តោះអាសន្ន) ត្រូវតែបានភ្ជាប់ជាមួយ SAD។ |
| 9 | អ្នកទទួលទំនិញ/អ្នកនាំចូលម្តងម្កាល | ជម្រើស | ប្រអប់នេះត្រូវបានបំពេញ សម្រាប់តែអ្នកទទួលទំនិញ ដែលមានលក្ខណៈម្តងម្កាលប៉ុណ្ណោះ ។ ក្នុងករណីនេះ អ្នកត្រូវបំពេញឈ្មោះអ្នកទទួលទំនិញ អត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋានក្នុងប្រអប់រងនៃអ្នកទទួលទំនិញម្តងម្កាល។<br>អ្នកទទួលទំនិញឬអ្នកនាំចូលម្តងម្កាល គឺជាបុគ្គល ឬ ក្រុមហ៊ុន ដែលធ្វើការនាំចូលតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីនេះក្រុមហ៊ុននឹងមិនមានលេខ អ.ត.ប ទេ។ ប្រសិនបើក្រុមហ៊ុនមានបំណងក្លាយជាអ្នកនាំចូលទៀងទាត់ នោះក្រុមហ៊ុនត្រូវមានលេខ អ.ត.ប |
| 10 | ប្រទេសមកពី/ទៅដល់ | ជម្រើស | នេះជាកូដប្រទេស ដែលទំនិញត្រូវបានផ្ទុកជាចុងក្រោយលើនាវា/អាកាសយាន (យន្តហោះ) ។ |
| 11 | | មិនតម្រូវ | នេះគឺជាប្រទេសដែល សហ-សហគ្រិនមៅការនៃអ្នកនាំចូល ត្រូវបានតាំងលំនៅ ឬមានរបរជំនួញរបស់ខ្លួន។ ចំពោះការនាំចូល ពាក្យ "ប្រទេសទិញទំនិញ" ត្រូវបានប្រើប្រាស់។<br>មិនទាន់ត្រូវការ សំរាប់ពេលបច្ចុប្បន្ននេះទេ។ |
| 12 | តម្លៃលំអិត | ចាំបាច់ | ប្រអប់នេះមានចន្លោះដើម្បីបញ្ចូលលំអិតនៃកម្រៃផ្សេងៗ (មិនត្រូវបានដាក់បញ្ចូលទៅក្នុងវិក្កយប័ត្រ) ដែលទាក់ទងទៅនឹងការគណនាតម្លៃគិតពន្ធគយនៃទំនិញ ។<br>ការពន្យល់:<br>ប្រសិនបើ មានការលក់រវាងអ្នកទិញនិងអ្នកលក់ ហើយថ្លៃលើវិក្កយប័ត្រ គឺក្នុងកម្រិត FOB បន្ទាប់មកការចំណាយផ្សេងៗ និងសោហ៊ុយដឹកទំនិញមកកាន់កម្ពុជា ត្រូវបានបូកបន្ថែមទៅលើតម្លៃ FOB ។ ការចំណាយ និងសោហ៊ុយផ្សេងៗ អាចជាសោហ៊ុយដឹកជញ្ជូនតាមអាកាស ឬសមុទ្រ ការធានារ៉ាប់រង សោហ៊ុយដឹកជញ្ជូនផ្សេងៗ ឬ សោហ៊ុយលើកដាក់ សោហ៊ុយពីទំនិញក្នុងស្រុក ។ល។ និង ត្រូវបូកបន្ថែមទៅក្នុងតម្លៃទំនិញនៅ"កន្លែង" ឬ "កម្រិត" ត្រឹមត្រូវ - CIF ប្រទេសនាំចូលដូចបង្ហាញខាងក្រោម:<br>ឧទាហរណ៍<br>វិក្កយប័ត្រសរុប (FOB) = ១០០០ USD<br>ថ្លៃដឹកជញ្ជូនខាងក្រៅ = ២០០ USD( 800 000 រៀល)<br>ធានារ៉ាប់រង = ៥០ USD ( 200 000 រៀល)<br>ថ្លៃដឹកជញ្ជូនខាងក្នុង = ៨០ ០០០រៀល<br>ដកចេញ = ១០៥ ០០០រៀល<br>តម្លៃលំអិត =៩៧៥ ០០០ រៀល (៨០០ ០០០+២០០ ០០០ + 80 000 - ១០៥ ០០០) |

| | | | |
|---|---|---|---|
| | | | ប្រសិនបើប្រព័ន្ធអាស៊ីគូដា និងប័ណ្ណកំណត់តម្លៃគិតពន្ធគយត្រូវបានប្រើ ប្រអប់តម្លៃលំអិតនេះ នឹងបង្ហាញដោយស្វ័យប្រវត្តិដោយប្រព័ន្ធ ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ឬ ប័ណ្ណកំណត់តម្លៃគិតពន្ធគយមិនត្រូវបានប្រើប្រាស់ ប្រតិវេទករត្រូវបញ្ចូលចំនួនទឹកប្រាក់នៃ "កម្រៃផ្សេងៗ" ។<br>កំណែតម្រូវសរុបចំពោះថ្លៃវិក្កយប័ត្រ ត្រូវបានបន្ថែមតាមសមាមាត្រទៅតាមមុខទំនិញដែលបានប្រកាស ក្នុងករណីដែលប្រតិវេទន៍មានច្រើនជាងមួយមុខទំនិញ ។ |
| 13 | អ.ទ.ម.ផ. | ចាំបាច់ | ប្រអប់នេះត្រូវបានប្រើសម្រាប់ទំនិញឆ្លងយន្តការ PSI<br>ឧទា: លេខ0=មិនជាប់ PSI, លេខ1=ឆ្លងPSI, លេខ2=មិនឆ្លង PSI<br>ក្នុងករណីតម្លៃ PSI=1 ត្រូវចុះលេខCRF នៅក្នុងមុខទំនិញទី1 |
| 14 | កូដប្រតិវេទករ / អ្នកតំណាង | ចាំបាច់ | ប្រតិវេទនករ គឺជាបុគ្គល ឬ ក្រុមហ៊ុន ឬអង្គការ ធ្វើការប្រកាសទំនិញចំពោះគយ។<br>នរណាអាចប្រកាស?<br>1. ក្នុងករណីនេះ អ្នកនាំចូលអាចបំពេញបែបបទយកទំនិញរបស់ខ្លួនបាន។ អ.ត.ប របស់ក្រុមហ៊ុនត្រូវតែបញ្ចូល (កូដក្រុមហ៊ុន និងកូដប្រតិវេទករដូចគ្នា) ។ ក្នុងករណីដែលអ្នកនាំចូលគ្មានលេខអ.ត.ប (អ្នកនាំចូលម្តងម្កាល) ប៉ុន្តែចង់ប្រកាសនាំចូលត្រូវប្រើប្រាស់ លេខកូដ ៩៩៩៩៩៩៩៩៩ ជាប្រតិវេទករម្តងម្កាល។ តែទោះជាយ៉ាងណាក៏ដោយ អ្នកទទួលទំនិញម្តងម្កាល មិនអាចជាប្រតិវេទករម្តងម្កាលក្រៅពីរបស់ខ្លួនបានទេ ។ ក្នុងករណីដោយឡែកនេះ ប្រសិនបើអ្នកនាំចូលទំនិញម្តងម្កាលមិនចង់ប្រកាសទំនិញរបស់ខ្លួនទេនោះ ម្ចាស់ទំនិញនោះត្រូវប្រើប្រាស់សេវាជើងសារគយ។<br>2. ជើងសារគយគឺជាអ្នកដែលត្រូវបានផ្តល់សិទ្ធិដោយម្ចាស់ទំនិញ ឲ្យបំពេញបែបបទយកទំនិញចេញពីគយក្នុងនាមម្ចាស់ទំនិញ ត្រូវតែបញ្ចូលកូដ អ.ត.ប ជើងសារគយមានការអនុញ្ញាត ។<br>នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ ឈ្មោះពេញ និងអាសយដ្ឋាននៃប្រតិវេទករ ត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើ SAD ។<br>ប្រសិនបើ SAD ត្រូវប្រើដោយដៃ ប្រតិវេទករត្រូវបំពេញឈ្មោះ និងអាសយដ្ឋានរបស់ខ្លួន ។ |
| 15 | ប្រទេសនាំចេញ | ចាំបាច់ | ប្រសិនបើប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ ឈ្មោះប្រទេសនាំចេញ នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ ប្រតិវេទករត្រូវបំពេញឈ្មោះប្រទេសនាំចេញ ផ្អែកតាមបញ្ជីយោងលេខកូដ ដែលបានផ្តល់អោយ ។<br>ប្រសិនបើ SAD ប្រើដោយដៃ ប្រតិវេទករត្រូវបំពេញឈ្មោះប្រទេសនាំចេញផ្អែកតាមបញ្ជីយោងលេខកូដដែលបានផ្តល់អោយ។ |

| | | | |
|---|---|---|---|
| 15 | កូដប្រទេសនាំចេញ | ចាំបាច់ | កូដប្រទេសនាំចេញមានពីរផ្នែក:<br>ផ្នែកទី១ លោកអ្នកត្រូវបញ្ចូលកូដប្រទេស (មិនមែនឈ្មោះប្រទេសទេ) ដែលបានធ្វើការនាំចេញទំនិញ ។<br>ផ្នែកទី២ តំបន់នៃប្រទេសនាំចេញ(ប្រអប់នេះមិនបាច់បំពេញ)។ |
| 16 | ប្រទេសដើមកំណើតទំនិញ | ចាំបាច់ | ប្រសិនបើមុខទំនិញនីមួយៗក្នុងប្រអប់លេខ ៥ មានប្រទេសដើមកំណើតទំនិញដូចគ្នា (ប្រអប់៣៤) ឈ្មោះប្រទេសនឹងបង្ហាញស្វ័យប្រវត្តិដោយប្រព័ន្ធក្នុងប្រអប់លេខ ១៦ ។<br>ប្រសិនបើមុខទំនិញនីមួយៗក្នុងប្រអប់លេខ៥ មានប្រទេសដើមកំណើតទំនិញខុសគ្នា (ប្រអប់៣៤) ប្រព័ន្ធនឹងបង្ហាញពាក្យ "ច្រើន" ក្នុងប្រអប់លេខ ១៦ ។<br>អនុវត្តវិធានដូចគ្នា ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ។ |
| 17 | កូដប្រទេសគម្យដ្ឋាន | ចាំបាច់<br><br><br><br>មិនតម្រូវ | កូដប្រទេសគម្យដ្ឋានមានពីរផ្នែក:<br>ផ្នែកទី១ នៅពេលនាំចូល ប្រទេសគម្យដ្ឋានជាប្រទេសនៃទីតាំងនាំចូលដែលជាកម្ពុជា។ ពាក្យ KH កូដប្រទេស ត្រូវបានបង្ហាញជាស្វ័យប្រវត្តិដោយប្រព័ន្ធ។<br>ប្រសិនបើ SAD ត្រូវបានប្រើដោយដៃ ប្រតិវេទករ ត្រូវបញ្ចូល KH ក្នុងប្រអប់នេះ ។<br>ផ្នែកទី២ តំបន់នៃប្រទេសគម្យដ្ឋាន (ប្រអប់នេះមិនត្រូវបានបញ្ចូល និង មិនត្រូវបានជ្រើសរើស XX) |
| 17 | ប្រទេសគម្យដ្ឋាន | ចាំបាច់ | នៅពេលដែលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ឈ្មោះ "កម្ពុជា" ត្រូវបានបង្ហាញជាស្វ័យប្រវត្តិ។<br>ប្រសិនបើ SAD ប្រើដោយដៃ ប្រតិវេទករត្រូវវាយបញ្ចូល "កម្ពុជា"។ |
| 18 | អត្តសញ្ញាណនិងសញ្ជាតិ មធ្យោបាយដឹកជញ្ជូនទៅ/មក | ចាំបាច់<br><br><br><br>ជម្រើស | ប្រអប់នេះចែកជាពីរផ្នែក:<br>ផ្នែកទី១ ត្រូវតែបំពេញជាមួយអត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនដែលដឹកជញ្ជូនទំនិញឆ្ពោះទៅប្រទេសគម្យដ្ឋាន។ ចំពោះនាវាអាចជាឈ្មោះនាវា ឬលេខវេនជើងនាវានោះ ។ ចំពោះយន្តហោះវាអាចជាលេខជើងហោះហើរ ចំពោះរថយន្តដឹកទំនិញ អាចជាស្លាកលេខ/ លេខអាជ្ញាប័ណ្ណ ។ល។ ផ្នែកនៃប្រអប់ ១៨ នេះ គឺចាំបាច់ ។<br>ផ្នែកទី២ សញ្ជាតិបង្ហាញជាកូដប្រទេសដែលមធ្យោបាយដឹកជញ្ជូននោះបានចុះបញ្ជី។ ផ្នែកនេះនៃប្រអប់ ១៨ គឺជម្រើស ប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។ |
| 19 | ការបង្ហាញកុងតឺន័រ | ជម្រើស | ប្រអប់នេះគឺបង្ហាញថាតើទំនិញបានប្រកាស ត្រូវបានដឹកជញ្ជូនតាមកុងតឺន័រ (ផ្ទុកក្នុងកុងតឺន័រ) ឬ មិនផ្ទុកក្នុងកុងតឺន័រ មិនសំដៅលើបរិមាណកុងតឺន័រទេ។ សូមគូសសញ្ញា √ ក្នុងប្រអប់នេះបើសិនទំនិញផ្ទុកក្នុងកុងតឺន័រ។ |

| | | | |
|---|---|---|---|
| 20 | ល័ក្ខខ័ណ្ឌប្រគល់ទទួល | <br><br>ចាំបាច់<br><br>ចាំបាច់<br><br>មិនតម្រូវ | ល័ក្ខខ័ណ្ឌបានព្រមព្រៀងទទួលយក រវាងអ្នកលក់និងអ្នកទិញ ចំពោះការប្រគល់ទំនិញដល់អ្នកទិញ។ ល័ក្ខខ័ណ្ឌប្រគល់ទទួល ក្នុងពាណិជ្ជកម្មអន្តរជាតិត្រូវបានចែងក្នុងវាក្យស័ព្ទពាណិជ្ជកម្មអន្តរជាតិ INCOTERMS។<br>ប្រអប់នេះមាន ៣ ផ្នែក:<br>**ផ្នែកទី១** ក្នុងប្រអប់នេះលោកអ្នកត្រូវបញ្ចូលកូដល័ក្ខខ័ណ្ឌប្រគល់ទទួល រៀបរាប់ល័ក្ខខ័ណ្ឌប្រគល់ទទួលដែលបានបញ្ជាក់ក្នុងកិច្ចសន្យាលក់ទំនិញរវាងអ្នកទិញនិងអ្នកលក់ នៃទំនិញដែលបានប្រកាស ដូចជា CIF, FOB, CFR ។ល។<br>**ផ្នែកទី២** ក្នុងប្រអប់នេះអ្នកត្រូវបញ្ចូលល័ក្ខខ័ណ្ឌប្រគល់ទទួល<br>**ទីកន្លែង:** ដូចជាក្រុងព្រះសីហនុ<br>**ផ្នែកទី៣** ប្រអប់នេះ គឺជាល័ក្ខខ័ណ្ឌប្រគល់ទទួលបង្ហាញជាកូដ មិនតម្រូវអោយបំពេញ និងត្រូវបានកំណត់ដោយ xx ។ |
| 21 | អត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ | <br>ជម្រើស<br><br>ជម្រើស | ប្រអប់នេះមានពីរផ្នែក:<br>**ផ្នែកទី១** ត្រូវបានបំពេញនូវអត្តសញ្ញាណមធ្យោបាយដឹកជញ្ជូនបានប្រើប្រាស់ក្នុងការឆ្លងកាត់ព្រំដែននៃប្រទេសតម្បដ្ឋានចុងក្រោយ។ សំរាប់នាវាវាអាចជាឈ្មោះនាវា ឬលេខវេនជើងធ្វើដំណើរ សំរាប់យន្តហោះវាអាចជាលេខជើងហោះហើរ សំរាប់រថយន្តដឹកវាអាចជាលេខចុះបញ្ជី/អាជ្ញាប័ណ្ណ។ល។ ប្រអប់នេះគឺជាការជ្រើសរើស ប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។<br>**ផ្នែកទី២** សញ្ជាតិបង្ហាញជាកូដប្រទេស មធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលត្រូវបានចុះបញ្ជី។ ប្រអប់នេះគឺជ្រើសរើសប៉ុន្តែប្រសិនបើអ្នកមានព័ត៌មានសូមបំពេញ។ |
| 22 | រូបិយបណ្ណ៍ & តំលៃវិក្កយបត្រសរុប | <br>ចាំបាច់<br><br>ចាំបាច់ | ប្រររប់ឆេះហាន២ផ្នែក:<br>**ផ្នែកទី១** អ្នកត្រូវបញ្ចូលកូដរូបិយវត្ថុដែលបានចុះក្នុងវិក្កយបត្រ<br>**ផ្នែកទី២** លោកអ្នកត្រូវបញ្ចូលចំនួនទឹកប្រាក់ជារូបិយប័ណ្ណសរុប (មិនទាន់ប្តូរ) ដូចបានប្រកាសក្នុងវិក្កយបត្រ។ |
| 23 | អត្រាប្តូរប្រាក់ | ចាំបាច់ | ប្រអប់នេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការ សំរាប់រូបិយប័ណ្ណ ដែលទំនិញក្នុងប្រអប់នេះ ត្រូវបានបង់ជាប្រាក់រៀល។<br>ការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា អត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅពេលដែលចំនួនប្រាក់ក្នុងវិក្កយបត្រសរុបត្រូវបានបញ្ចូល។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទករត្រូវបញ្ចូលអត្រាប្តូរប្រាក់ ដែលមាននៅគ្រប់ការិយាល័យគយ។ |

| | | | |
|---|---|---|---|
| | | | អត្រាប្តូរប្រាក់ផ្លូវការត្រូវបានដាក់បញ្ចូលថ្មីជារៀងរាល់ថ្ងៃសុក្រនិងត្រូវផ្តល់សុពលភាពនៅថ្ងៃច័ន្ទ។ |
| 24 | ប្រភេទចម្លងការ | ជម្រើស | ប្រភេទចម្លងការ គឺជាការបង្ហាញដល់គយនូវប្រភេទនៃកិច្ចសន្យា ដែលទំនិញត្រូវបានផ្គត់ផ្គង់ ដូចជាការលក់ ការផ្លាស់ប្តូរ អំណោយ កម្ចី ជួលទំនិញត្រឡប់វិញ។ល។<br>ប្រអប់នេះមាន២ផ្នែក:<br>**ផ្នែកទី១** ការបរិយាយទូទៅនៃកិច្ចចម្លងការ<br>ឧទាហរណ៍: ២ កម្ចីដោយមានការប្រាក់<br>**ផ្នែកទី២** លំអិតនៃកិច្ចចម្លងការ<br>ឧទាហរណ៍: ១ កម្ចី ឬ ជួល<br>២ ភតិសន្យា (កិច្ចសន្យាជួល) |
| 25 | បែបផែនដឹកជញ្ជូននៅព្រំដែន | ចាំបាច់ | បែបផែនដឹកជញ្ជូន បានប្រើសំរាប់ដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន។ អ្នកត្រូវបញ្ចូលក្នុងបែបផែនដឹកជញ្ជូននៃការនាំចូលទំនិញ។<br>ឧទាហរណ៍:<br>១. ទំនិញមកដល់តាមនាវានៅក្រុងព្រះសីហនុ → ប្រអប់២៥(បែបផែនដឹកជញ្ជូននៅព្រំដែន) = ១ (ដឹកជញ្ជូនតាមសមុទ្រ) បន្ទាប់មកដាក់លើរថយន្តដឹកជញ្ជូនទៅភ្នំពេញ → ប្រអប់២៦(បែបបផែនដឹកជញ្ជូនតាមផ្លូវគោក) = ៣ (ដឹកជញ្ជូនតាមផ្លូវថ្នល់)<br>២. ទំនិញមកដល់ ដឹកជញ្ជូនតាមផ្លូវទឹកពីប្រទេសវៀតណាម → ប្រអប់២៥ (បែបផែនដឹកជញ្ជូននៅព្រំដែន) = ៨ (ដឹកជញ្ជូនតាមផ្លូវទឹកចូលមកក្នុងដែនគយ) បន្ទាប់មកតាមបែបផែនដឹកជញ្ជូនដដែលនេះឆ្ពោះទៅកំពង់ផែភ្នំពេញ → ប្រអប់២៦ (បែបបផែនដឹកជញ្ជូនតាមផ្លូវទឹកចូលមកដែនគោក) = ៨ (ដឹកជញ្ជូនតាមផ្លូវទឹកចូលមកដែនគោក)។ |
| 26 | បែបផែនដឹកជញ្ជូនដែនគោក | ជម្រើស | បែបផែនដឹកជញ្ជូនបានប្រើប្រាស់នៅពេលដឹកជញ្ជូនទំនិញនាំចូល បន្តទៅក្នុងដែនគោក (ហួសពីព្រំដែន)។ |
| 27 | ទីកន្លែងផ្ទុក/ផ្ទេរ | ជម្រើស | ឈ្មោះកំពង់ផែសមុទ្រ ព្រលានយន្តហោះ ស្ថានីយ៍បញ្ជូនទំនិញ ស្ថានីយ៍រថភ្លើង ឬ ទីកន្លែងផ្សេងទៀត ដែលទំនិញត្រូវបានផ្ទេរចេញពីមធ្យោបាយដឹកជញ្ជូន ហើយត្រូវបានប្រើប្រាស់សំរាប់ដឹកជញ្ជូនទំនិញ។<br>ប្រអប់នេះរួមមាន២ ផ្នែក:<br>**ផ្នែកទី១** ត្រូវបានបំពេញជាមួយកូដក្រុង (ឧទាហរណ៍ BBM សំរាប់ឈ្មោះខេត្តបាត់ដំបង)។<br>**ផ្នែកទី២** ត្រូវបានបំពេញជាមួយកូដប្រទេស (ឧទាហរណ៍ KH សំរាប់ |

| | | | |
|---|---|---|---|
| | | | ប្រទេសកម្ពុជា)។ |
| 28 | ព័ត៌មានហិរញ្ញវត្ថុនិង ធនាគារ (កូដធនាគារ ល័ក្ខខ័ណ្ឌទូទាត់ ឈ្មោះ ធនាគារ សាខា លេខ ឯកសារ | | ប្រអប់នេះ ពាក់ព័ន្ធជាមួយព័ត៌មានធនាគារ និងហិរញ្ញវត្ថុ ដូចជាឈ្មោះធនាគារ តាមរយៈការទូទាត់ទំនិញត្រូវបានធ្វើឡើង និង លក្ខខណ្ឌទូទាត់។<br>ប្រអប់នេះមាន៥ផ្នែក: |
| | | ជម្រើស | **ផ្នែកទី១** (កូដធនាគារ) ក្នុងការអវត្តមាននៃកូដធនាគារពិសេស លេខ អ.ត.ប ធនាគារនីមួយៗ ត្រូវបានប្រើជាកូដធនាគារ។ |
| | | ជម្រើស | **ផ្នែកទី២** (ល័ក្ខខ័ណ្ឌទូទាត់) ការព្រមព្រៀងណាមួយរវាងអ្នកនាំចូលនិងអ្នកនាំចេញលើការទូទាត់ទំនិញ (មិនមានពាក់ព័ន្ធទៅនឹងការទូទាត់ពន្ធ និងអាករទេ)។ |
| | | ជម្រើស | **ផ្នែកទី៣** (ឈ្មោះធនាគារ) នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ឈ្មោះធនាគារនឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តនៅពេលកូដ ធនាគារត្រូវបានបញ្ចូល។<br>នៅពេលអាស៊ីគូដាត្រូវបានប្រើដោយដៃ ប្រតិវេទនករត្រូវបំពេញឈ្មោះធនាគារ។ |
| | | ជម្រើស | **ផ្នែកទី៤** (សាខាធនាគារ) បច្ចុប្បន្ននៅកម្ពុជា សាខាធនាគារមិនត្រូវបានដាក់កូដទេ។ ប៉ុន្តែឈ្មោះរបស់វាត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ ។ |
| | | មិនតម្រូវ | **ផ្នែកទី៥** (លេខឯកសារ) លេខយោងឯកសារធនាគារ វាមិនត្រូវបានតម្រូវ ។ |
| 29 | ការិយាល័យ ចេញ/ចូល | ចាំបាច់ | ប្រអប់នេះ សំរាប់បំពេញកូដការិយាល័យគយ ទីកន្លែងដែលទំនិញបាននាំចូលមកក្នុងប្រទេសគម្យដ្ឋាន។ កូដការិយាល័យគយនេះអាចខុសពីការិយាល័យដាក់ប្រតិវេទន៍ដូចក្នុងប្រអប់ A (ការិយាល័យដាក់ប្រតិវេទន៍)។<br>នៅពេលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ការត្រួតពិនិត្យខាងក្រោមនេះនឹងត្រូវអនុវត្ត:<br>- ការិយាល័យនៃច្រកចូល/ចេញ គឺត្រូវស្របទៅនឹង "បែបផែនដឹកជញ្ជូននៅព្រំដែន" ក្នុងប្រអប់២៥ និង<br>- គឺត្រូវកានប្រកាសដូចការិយាល័យគយព្រំដែនដែរ។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទករត្រូវផ្ទៀងផ្ទាត់បែបផែនដឹកជញ្ជូន មានសុពលភាពសំរាប់ការិយាល័យចូល/ចេញ ដែលបានគូសបញ្ជាក់លើ SAD និងប្រភេទការិយាល័យគយ (ព្រំដែន ឬ មិនមែនព្រំដែន)។ |
| 30 | ទីតាំងនៃទំនិញ | ជម្រើស | ការបង្ហាញពីទីកន្លែងដែលទំនិញត្រូវបានផ្ទុកនិងទីកន្លែងដែលបានផ្តល់សំរាប់ការឆែកពិនិត្យ។ ទីនោះអាចជាទីបរិវេណសហគ្រាសរបស់អ្នកនាំចូល ឃ្លាំងបណ្តោះអាសន្ន ទូរថភ្លើង ទីលានកំពង់ផែ។ល។<br>ប្រអប់នេះ មិនត្រូវបានប្រើប្រាស់សំរាប់ប្រកាសពីភណ្ឌាគារគយដែល |

| | | | |
|---|---|---|---|
| | | | ទំនិញត្រូវបានរក្សាទុកក្រោយការនាំចូល។ |
| 31 | ព័ត៌មានកញ្ចប់និងបរិយាយមុខទំនិញ (ផ្លាកសញ្ញាលើកញ្ចប់ ចំនួន និងប្រភេទ អត្តសញ្ញាណកុងតេន័រ បរិយាយដូចក្នុងតារាងពន្ធគយ បរិយាយមុខទំនិញពាណិជ្ជកម្ម) | ជម្រើស | ប្រអប់នេះមានប្រាំផ្នែក:<br>**ផ្នែកទី១** (ផ្លាកសញ្ញាលើកញ្ចប់) ការបញ្ចូលព័ត៌មានក្នុងប្រអប់នេះត្រូវដាក់បញ្ចូលស្លាកសញ្ញានិងលេខ (២ប្រអប់) ធ្វើអត្តសញ្ញាណ កញ្ចប់ដោយឡែក លើកលែងតែទំនិញមិនមានការវេចខ្ចប់។<br>ចំពោះរថយន្ត:<br>(a) ត្រូវចុះចូលនូវលេខតួ<br>(b) ត្រូវចុះចូលនូវលេខម៉ាស៊ីន |
| | | ជម្រើស | **ផ្នែកទី២** (ចំនួននិងប្រភេទ) ចំនួនកញ្ចប់សំរាប់មុខទំនិញ នៅពេលដែលសរុបចំនួនកញ្ចប់តាមមុខទំនិញ ត្រូវតែស្មើនឹងចំនួនសរុបកញ្ចប់សំរាប់ SAD នេះ។ នៅពេលដែលទំនិញមានប្រភេទកញ្ចប់ពីរផ្សេងគ្នា មុខទំនិញពីរនឹងត្រូវបានបង្កើតលើ SAD (ប្រសិនបើទំនិញស្ថិតក្នុងលេខកូដដូចគ្នា ប៉ុន្តែមានកូដប្រភេទកញ្ចប់ខុសគ្នា)។ ត្រូវយកចិត្តទុកដាក់ជាពិសេស សំរាប់ឃ្លាំង ដែលកូដពិសេសនឹងត្រូវបានបន្ថែមពីភាពខុសគ្នានេះ។<br>• ការប្រើប្រភេទកូដនៃកញ្ចប់ «មិនមានការវេចខ្ចប់»<br>• លេខអនុញ្ញាតនៃកញ្ចប់គឺជម្រើស<br>• ការត្រួតពិនិត្យដោយវិធាន បើសិនជាចំនួនកញ្ចប់មិនបានបំពេញនូវកូដកញ្ចប់ទេ ប្រព័ន្ធមិនអនុញ្ញាតឱ្យប្រតិវេទន៍ដំណើរការទៅមុខទេ។<br>ឧទាហរណ៍: ស្រា និងប្រូមា ១ កាតុង<br>SAD: ចំនួនកញ្ចប់សរុប ១<br>មុខទំនិញទី១ - ស្រា - ចំនួនកញ្ចប់ = ១, ប្រភេទកញ្ចប់ = CT<br>មុខទំនិញទី២ - ប្រូមា - ចំនួនកញ្ចប់ = ១, ប្រភេទកញ្ចប់ = NE |
| | | ចាំបាច់ | កូដសំរាប់ប្រភេទកញ្ចប់ ត្រូវតែបញ្ចូលដូចជា ថង់ កាតុង។ល។ |
| | | ជម្រើស | **ផ្នែកទី៣** (អត្តសញ្ញាណកុងតេន័រ)<br>ប្រសិនបើមានមួយ ឬ បួនកុងតេន័រ សំរាប់មុខទំនិញជាក់លាក់នេះ: ប្រតិវេទនករត្រូវបញ្ចូលលេខអត្តសញ្ញាណកុងតេន័រ (ឧទាហរណ៍ 1234567 (45HQ) នៃកុងតឺន័រនិមួយៗ។<br>ប្រសិនបើមានកុងតឺន័រច្រើនជាងបួន សំរាប់មុខទំនិញជាក់លាក់នេះ: ប្រតិវេទករត្រូវបញ្ចូលចំនួនសរុបនៃកុងតឺន័រលើប្រអប់ទីមួយដែលមានស្រាប់ និងបញ្ចូល "បញ្ជីភ្ជាប់" ក្នុងប្រអប់ទី២។ ប្រតិវេទករ ត្រូវផ្តល់នូវទំព័រកុងតឺន័រ រាប់បញ្ចូលបញ្ជីនៃអត្តសញ្ញាណប្រភេទតែមួយនូវគ្រប់កុងតឺន័រ។ ទំព័រនេះត្រូវបានផ្តល់ដោយ ASYCUDA ប្រសិនបើប្រព័ន្ធត្រូវបានប្រើប្រាស់។ |

| | | | |
|---|---|---|---|
| | | <br>ចាំបាច់<br><br>ចាំបាច់ | សំរាប់ SAD បញ្ចូលដោយដៃ ប្រតិវេទករត្រូវប្រើ/បំពេញទំព័រកុងតឺន័ររាប់បញ្ចូលបញ្ជីនៃអត្តសញ្ញាណប្រភេទតែមួយ "Unique" នូវគ្រប់កុងតេន័រ។ ច្បាប់ចម្លងនៃទម្រង់ ASYCUDA ត្រូវបានផ្តល់ដូចខាងក្រោម:<br>**ផ្នែកទី៤** (បរិយាយមុខទំនិញដូចក្នុងតារាងពន្ធគយ) បរិយាយមុខទំនិញដូចក្នុងតារាងពន្ធគយនឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅលើបន្ទាត់ពីរដំបូងនៃប្រអប់ នៅពេលដែលប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើប្រាស់ (កំរិតអតិបរិមាត្រឹម៨៨តួអក្សរ)។<br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទនករត្រូវបញ្ចូលបរិយាយទំនិញនាំចូលដូចក្នុងតារាងពន្ធគយ។<br>**ផ្នែកទី៥** (បរិយាយមុខទំនិញពាណិជ្ជកម្ម) បន្ទាត់ទីបីនៃប្រអប់នេះ នឹងត្រូវបានបំពេញជាមួយនឹងបរិយាយមុខទំនិញពាណិជ្ជកម្មដូចក្នុងវិកយបត្រ។ វាក៏អាចបញ្ចូលផងដែរពីម៉ាកទំនិញ។ |
| 32 | មុខទំនិញទី | ចាំបាច់ | ប្រអប់នេះគឺជាលេខមុខទំនិញតាមលំដាប់សំរាប់ប្រតិទន៍នេះ: ឧទាហរណ៍ មុខទំនិញទី១ មុខទំនិញទី២ មុខទំនិញទី៣។ល។ |
| 33 | កូដទំនិញ | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញជាមួយនឹងកូដទំនិញ ដែលបានប្រកាសសំរាប់ (មុខទំនិញនិមួយៗ)នៅវិក្កយបត្រ ស្របតាមតារាងពន្ធគយកម្ពុជាជាធរមាន។<br>បួនខ្ទង់ចុងក្រោយ (ហៅថាការតំណាងអោយលេខ៥) អាចត្រូវបានប្រើប្រាស់សំរាប់ការគ្រប់គ្រងសន្និធិឃ្លាំង។<br>សូមយោងសៀវភៅតារាងពន្ធគយកម្ពុជាជាធរមាន |
| 34 | កូដប្រទេសដើមកំណើតទំនិញ | ចាំបាច់ | ប្រអប់នេះ ត្រូវបានបំពេញជាមួយកូដប្រទេសដែលទំនិញជាក់លាក់ ត្រូវបានប្រកាសពីទីកន្លែងដើមកំណើតដែលបានផលិត។ |
| 35 | ទម្ងន់ទាំងសំបក | ចាំបាច់ | ប្រអប់នេះត្រូវបំពេញនូវទម្ងន់ទំនិញដោយរាប់បញ្ចូលសំបកវេចខ្ចប់ ប៉ុន្តែមិនរាប់បញ្ចូលនូវបរិក្ខាដឹកជញ្ជូន ដូចជាកុងតេន័រ ឡាំង ប៉ាឡែត។ល។ ដែលបញ្ជាក់ជាគ.ក្រ។<br>អ្នកត្រូវបញ្ចូលទម្ងន់សរុបនៃទំនិញ (មិនមែនឯកតា) នៃមុខទំនិញ |
| 36 | ពន្ធអនុគ្រោះ | ជម្រើស | ប្រអប់នេះគឺសំរាប់អត្រាពន្ធអនុគ្រោះដោយផ្អែកលើកិច្ចព្រមព្រៀងបានធ្វើឡើងរវាងកម្ពុជានិងបណ្តាប្រទេសនានា ដូចជា CEPT ។ |
| 37 | របបគយ | <br>ចាំបាច់ | ប្រអប់នេះមានពីរផ្នែក:<br>**ផ្នែកទី១** គឺត្រូវបានបំពេញជាមួយកូដរបបបានប្រើប្រាស់ដើម្បីកំណត់របបគយដែលទំនិញត្រូវបាននាំចូល នាំចេញ ឧទាហរណ៍ របប ៤០០០ តំណាងអោយការនាំចូលស្ថាពរដើម្បីប្រើប្រាស់ក្នុងស្រុក របប ៤០៧១ ដាក់អោយប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីបានដាក់ចូលក្នុងភណ្ឌាគារគយ។ល។ |

| | | | |
|---|---|---|---|
| | | ចាំបាច់ | ផ្នែកទី២ គឺជាកូដរបបបន្ថែម បានប្រើប្រាស់ដើម្បីកំណត់របបរួមឬការលើកលែងពន្ធណាមួយ។<br>នីតិវិធីទាំងពីរខាងលើត្រូវតែឯកភាពគ្នា |
| 38 | ទម្ងន់សុទ្ធ | ចាំបាច់ | ប្រអប់នេះត្រូវបំពេញនូវទម្ងន់សុទ្ធគិតជាគ.ក្រ. នៃទំនិញដែលបានប្រកាស។ ប្រព័ន្ធនឹងបង្ហាញដោយស្វ័យប្រវត្តនូវតួលេខទម្ងន់សរុបដូចទម្ងន់សុទ្ធ។ ប៉ុន្តែអ្នកអាចសរសេរត្រួតគ្នា នៅក្នុងប្រអប់នេះជាមួយនឹងទម្ងន់សុទ្ធ។ |
| 39 | | មិនតម្រូវ | ប្រអប់នេះសំរាប់ការយោងចំពោះទំនិញដែលអនុវត្តកូតាណាមួយ ប្រអប់នេះមិនតម្រូវសំរាប់ពេលបច្ចុប្បន្ននេះទេ។ |
| 40 | ឯកសារដឹកជញ្ជូនឬប្រតិវេទន៍យោងពីមុន | ជម្រើស | ប្រអប់នេះសំរាប់បំពេញដូចខាងក្រោម៖<br>លេខអញ្ញាត្តប័ណ្ណ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាស ឬ Parcels Notification Duty Entry សំរាប់កិច្ចប្រតិបត្តិការគយដោយផ្ទាល់ ឬការយោងប្រតិវេទន៍ពីមុនសំរាប់កិច្ចប្រតិបត្តិការគយប្រយោល ។<br>ឧទាហរណ៍<br>ទំនិញត្រូវបាននាំចូលតាមផ្លូវអាកាស ហើយដាក់ចូលដោយផ្ទាល់ទៅក្នុងឃ្លាំង។ កិច្ចប្រតិបត្តិការនេះ ត្រូវបានចាត់ទុកថាជាកិច្ចប្រត្តិបត្តិការនាំចូលដោយផ្ទាល់ និងកូដរបបគយគឺ ៧១០០។ លេខអញ្ញាត្តប័ណ្ណតាមផ្លូវអាកាសនឹងត្រូវបានបញ្ចូលទៅក្នុងប្រអប់ ៤០ ដើម្បីកាត់ចេញ។<br>បន្ទាប់មក ទំនិញដដែលនេះត្រូវបានយកចេញពីឃ្លាំង និងដាក់លក់ក្នុងទីផ្សារ។ ប្រតិបត្តិការនេះមិនមែនជាប្រត្តិបត្តិការនាំចូលដោយផ្ទាល់នោះទេ ប៉ុន្តែជាការនាំចូលប្រើប្រាស់ក្នុងស្រុកបន្ទាប់ពីបានដាក់ចូលក្នុងឃ្លាំង ដូចនេះរបបគយគឺ ៤០៧១ ។ ការយោងប្រតិវេទន៍ដើម ៧១០០ នឹងត្រូវបានដាក់បញ្ចូលក្នុងប្រអប់ ៤០ សំរាប់តែជាព័ត៌មានតែប៉ុណ្ណោះ។ |
| 41 | ឯកតារង | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញនៅពេលចំណាត់ថ្នាក់តារាងពន្ធគយតាមមុខទំនិញដែលកំពុងប្រើប្រាស់តម្រូវអោយមានឯកតារងក្រៅពីទម្ងន់សុទ្ធដូចជា លីត្រ ចំនួន ឡូ ។ល។ មានតែបរិមាណមួយគត់ត្រូវបានបំពេញក្នុងប្រអប់នេះ ឯកតាមិនត្រូវបានដាក់បញ្ចូលទេ។<br>ឧទាហរណ៍<br>i) លេខកូដ 87120010 (កង់ប្រណាំង) ឯកតារង = Unit ដូចនេះប្រអប់ នេះត្រូវបំពេញចំនួនកង់ដែលនាំចូល (ឧ. ៤៣ Unit)។ |
| 42 | តម្លៃឯកតា(តាមមុខទំនិញ) | ចាំបាច់ | ប្រអប់នេះត្រូវបានបំពេញជាមួយតម្លៃតាមមុខទំនិញគិតជារូបិយប័ណ្ណ។<br>វាត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ នៅពេលអនុវត្តប្រព័ន្ធអាស៊ីគូដានិងកំណត់សំគាល់តម្លៃត្រូវបានប្រើប្រាស់។ មិនដូច្នេះទេ តម្លៃតាមមុខទំនិញត្រូវបានបញ្ចូលដោយដៃ។ |
| 43 | វិធីកំណត់តម្លៃ | ជម្រើស | ប្រអប់នេះត្រូវបំពេញកូដនៃវិធីកំណត់តម្លៃ (១ដល់៦ និង៩) ត្រូវបានប្រើ |

| | | | |
|---|---|---|---|
| | | | ប្រាស់ដើម្បីកំណត់តម្លៃគិតពន្ធគយ។ |
| 44 | ព័ត៌មានបន្ថែម | ជម្រើស<br>ចាំបាច់<br>ជម្រើស | ប្រអប់នេះត្រូវបានប្រើប្រាស់សំរាប់ព័ត៌មានបន្ថែមណាមួយ ដូចជាវិញ្ញាបនបត្របញ្ជាក់ការផលិត លិខិតអនុញ្ញាត។ល។ វាមានប្រអប់រងជាច្រើន៖<br>- លេខអាជ្ញាប័ណ្ណ<br>- តម្លៃកាត់បន្ថយ (DV) និងបរិមាណកាត់បន្ថយ (DQ)<br>កំណត់សំគាល់: ASYCUDA មិនគ្រប់គ្រងតម្លៃ និងបរិមាណ សំរាប់អាជ្ញាប័ណ្ណទេ។ តម្លៃ និងបរិមាណត្រូវកាត់បន្ថយនឹងមិនត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជាសំរាប់ពេលបច្ចុប្បន្ននេះទេ វាគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។<br>- តម្លៃលំអិត (ប័ណ្ណកំណត់តម្លៃ) នឹងត្រូវបង្ហាញដោយស្វ័យប្រវត្តិនៅពេលប្រើប្រព័ន្ធ ASYCUDA។<br>- ឯកសារយោង (កូដនៃឯកសារបន្ថែម វិញ្ញាបនប័ត្រ ឬលិខិតអនុញ្ញាតបន្ថែមណាមួយ ដែលតម្រូវសំរាប់ការបញ្ចេញទំនិញណាមួយ ដូចជាតម្រូវការចត្តាឡីស័កវិញ្ញាបនប័ត្រសុខភាព។ល។<br>នៅពេលប្រព័ន្ធអាស៊ីគូដា ត្រូវបានប្រើប្រាស់ កូដនឹងត្រូវបានបន្ថែមដោយស្វ័យប្រវត្តិទៅតាមកូដដែលបានបញ្ចូលទៅក្នុងប្រព័ន្ធ (ឧទា.វិញ្ញាបនបត្រដើមកំណើតទំនិញ-ប្រយោជន៍ពីអគ្រាពន្ធអនុគ្រោះ។<br>ប្រសិនបើកូដឯកសារភ្ជាប់ ត្រូវបានបំពេញដោយប្រតិវេទករ ទៅក្នុងទំព័រនៃឯកសារភ្ជាប់ វាមិនបានបង្ហាញជាមួយ SAD ទេ។<br>ប្រអប់ទំនេរសំរាប់បញ្ចូលព័ត៌មានបន្ថែម ដូចជា: វិក្កយបត្របញ្ជីវេចខ្ចប់ លេខយោង។ល។ |
| 45 | ការកែតម្រូវ | ចាំបាច់ | ការកែតម្រូវ គឺជាអនុបាត/កត្តាអនុវត្តតម្លៃគិតពន្ធគយ។ តាមការកំណត់ជាមុន (Default) ការកែតម្រូវគឺ១។ ប្រតិវេទនករមិនតម្រូវឲ្យផ្លាស់ប្តូរតម្លៃនេះទេ។ |
| 46 | តំលៃគិតពន្ធគយ | ចាំបាច់ | ប្រអប់នេះបរិយាយពីតម្លៃគិតពន្ធគយ។ ប្រអប់នេះនឹងត្រូវបានបំពេញតម្លៃជាលុយរៀលនៃទំនិញដែលបានបរិយាយក្នុងប្រអប់៣១ ផ្អែកតាមវិធានតម្លៃគិតពន្ធគយក្រោមច្បាប់ស្តីពីគយ។<br>តម្លៃនេះ គឺជាថ្លៃទំនិញដែលបានកែតម្រូវអោយត្រូវតាមកត្តាតម្លៃនៅពេលមកដល់គិតជា CIF។ |
| 47 | ការគណនាពន្ធ | ចាំបាច់ | ប្រអប់នេះរួមមានកត្តាពាក់ព័ន្ធទៅនឹងការគណនាពន្ធ ដូចមានក្នុងចំណុចខាងក្រោម៖<br>i) ប្រភេទ<br>ប្រភេទពន្ធ ឬអាករ ដែលអាចអនុវត្តក្រោមច្បាប់កម្ពុជាដូចជាពន្ធនាំចូល |

| | | | |
|---|---|---|---|
| | | | ពន្ធនាំចេញ អាករ អាករលើតម្លៃបន្ថែម។ល។<br>**ii) មូលដ្ឋានពន្ធ**<br>មូលដ្ឋានពន្ធ គឺជាតម្លៃគិតពន្ធគយនៅពេលដែលចំនួនប្រាក់ពន្ធ/អាករ កំណត់ដោយគយផ្អែកតាមមូលដ្ឋាននៃការគណនា។<br>**iii) អត្រា**<br>អត្រាពន្ធ/អាករត្រូវផ្អែកលើមូលដ្ឋានកូដតារាងពន្ធគយសំរាប់មុខទំនិញជាក់លាក់ណាមួយ។<br>**iv) ចំនួនប្រាក់ពន្ធ**<br>សរុបចំនួនប្រាក់ពន្ធ/អាករ ត្រូវបានគណនាលើមុខទំនិញផ្អែកតាមអត្រាពន្ធ/អាករ។<br>**v) បែបផែនទូទាត់**<br>ប្រអប់នេះបង្ហាញថាពន្ធត្រូវបង់(១) ត្រូវបានធានា(៣) ឬ ត្រូវបានគណនាសំរាប់តែជាព័ត៌មាន(0)។ |
| 48 | ការទូទាត់ជាក្រោយ | ជម្រើស | ប្រសិនបើការទូទាត់ជាក្រោយត្រូវបានប្រើប្រាស់ ប្រអប់នេះត្រូវបានបំពេញជាមួយលេខគណនីឥណទានឬលេខគណនីទូទាត់ជាមុន។ |
| 49 | អត្តសញ្ញាណឃ្លាំងទំនិញ | | ប្រអប់នេះសំដៅលើនីតិវិធីព្យួរពន្ធ។ ប្រសិនបើនីតិវិធីគយមិនមែនជានីតិវិធីព្យួរពន្ធ ប្រអប់នេះមិនត្រូវបានប្រើ។<br>ប្រអប់នេះមានពីរផ្នែក:<br>ផ្នែកទី១- គឺបញ្ចូលកូដឃ្លាំង ឧ. អត្តសញ្ញាណឃ្លាំងដែលទំនិញនឹងត្រូវបានដាក់បញ្ចូល។<br>ចាំបាច់សម្រាប់តែរបបព្យួរពន្ធ។ មិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។<br>ផ្នែកទី២- គឺបញ្ចូលរយៈពេល (ចំនួនថ្ងៃ) ដែលទំនិញត្រូវបានអនុញ្ញាតអោយស្តុកទុកក្នុងឃ្លាំងណាមួយ។<br>ចាំបាច់សម្រាប់តែរបបព្យួរពន្ធ ឬមិនចាំបាច់សម្រាប់ករណីផ្សេងពីនេះ។ |
| B | គណនេយ្យលំអិត | ចាំបាច់ | ប្រអប់នេះត្រូវបានប្រើប្រាស់សំរាប់ព័ត៌មានដែលទាក់ទងនឹងគណនេយ្យ ដូចជាបែបបផែនទូទាត់ លេខវាយតម្លៃ លេខបង្កាន់ដៃ និងការធានា ដូចខាងក្រោម:<br>**i) បែបផែនទូទាត់**<br>បែបផែនទូទាត់ (ប្រអប់ B) ត្រូវប្រើភ្ជាប់នឹងប្រអប់ 48។ ប្រសិនបើ ប្រអប់ 48 មិនបានបំពេញ មានន័យថាប្រាក់ពន្ធ និងអាករត្រូវបានទូទាត់ភ្លាមៗ (ឬ បង់សាច់ប្រាក់)។ ប្រសិនបើប្រអប់ 48 ត្រូវបានបំពេញដោយលេខមូលប្បទានប័ត្រ ឬលេខគណនី មានន័យថាពន្ធ និងអាករត្រូវបានទូទាត់ជាក្រោយ។ |

| | | | |
|---|---|---|---|
| | | | **ii) លេខវាយតម្លៃ**<br>ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខវាយតម្លៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីបញ្ចប់ការវាយតម្លៃ។<br>ចំពោះការបំពេញប្រតិវេទន៍ដោយដៃមិនមានលេខវាយតម្លៃនេះទេ។<br>**iii) លេខបង្កាន់ដៃ**<br>ប្រព័ន្ធ ASYCUDA នឹងផ្តល់លេខវាយតម្លៃដោយស្វ័យប្រវត្តិនៅលើប្រតិវេទន៍ក្រោយពីការទូទាត់ពន្ធ និងអាករួច។<br>ចំពោះការបំពេញប្រតិវេទន៍ដោយដៃ គណនេយ្យករត្រូវសរសេរលេខបង្កាន់ដៃពន្ធនៅលើប្រតិវេទន៍ ។<br>**iv) ការធានា**<br>ប្រព័ន្ធ ASYCUDA នឹងបង្ហាញចំនួនប្រាក់ពន្ធ និងអាករសរុបដែលធានានៅលើប្រតិវេទន៍។<br>ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវចំនួនប្រាក់ពន្ធ និងអាករដែលធានានៅលើប្រតិវេទន៍។<br>**v) កម្រៃសរុប**<br>បើសិនជាមានកម្រៃដែលត្រូវទូទាត់ច្រើនប្រភេទ(កម្រៃPSI + កម្រៃពីការលក់ប្រតិវេទន៍)ប្រអប់ B ត្រូវបំពេញនូវកម្រៃសរុបដែលត្រូវទូទាត់។<br>ចំពោះការប្រើប្រព័ន្ធ កម្រៃនីមួយៗត្រូវបានបង្ហាញនៅលើប័ណ្ណវាយតម្លៃ។<br>ការប្រើ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញនូវកម្រៃនីមួយៗនៅខាងក្រោមប្រអប់ D។<br>**vi) ប្រាក់ពន្ធសរុបលើប្រតិវេទន៍**<br>សរុបចំនួនប្រាក់ពន្ធ អាករ និងកម្រៃផ្សេងៗ ត្រូវបង់សំរាប់ប្រតិវេទន៍នេះ (សរុបពន្ធ / អាករ + សរុបកម្រៃ) |
| 54 | ហត្ថលេខា និងឈ្មោះប្រតិវេទនករ/អ្នកតំណាង | ចាំបាច់ | ឈ្មោះ កាលបរិច្ឆេទ និងហត្ថលេខាប្រតិវេទនករ/អ្នកតំណាង។ |
| 50 51 52<br>53<br>C D | | | បំរុងទុកសំរាប់ប្រើនាពេលអនាគត |

## II. កំណាត់ពន្យល់ប្រភេទទន័គយនាំចេញ (ឯកសាររដ្ឋបាលតែមួយ)

ឯកសាររដ្ឋបាលតែមួយ (SAD) គឺជាឯកសារតែមួយប្រើសម្រាប់គ្រប់របបបញ្ចេញទំនិញពីគយ ការនាំចូល ការនាំចេញ ភណ្ឌាគារគយ ។ល។ ផ្នែកនេះបង្ហាញលំអិតអំពីរបៀបបំពេញ SAD សំរាប់ប្រតិវេទន៍គយនាំចេញ ។

ប្រតិវេទន៍គយនាំចេញមាន:

- ការនាំចេញ - EX1
- ការនាំចេញបណ្ដោះអាសន្ន - EX2
- ការនាំចេញទៅវិញ - EX3
- នីតិវិធីនាំចេញដទៃទៀត- EX9

ប្រអប់និមួយៗនៃ SAD ត្រូវបានរៀបចំឡើង ដែលជាការបញ្ចូលចាំបាច់ (វាត្រូវតែបំពេញ) បញ្ចូលដោយជ្រើសរើស(បំពេញប្រសិនបើមានពាក់ព័ន្ធ) ឬក្នុងករណីខ្លះប្រអប់អាចមិនចាំបាច់បំពេញ(មិនត្រូវការប្រើប្រាស់)។

ផ្នែកខាងក្រោមនេះ រៀបរាប់លំអិតពីគោលបំណងនៃប្រអប់និមួយៗនៃ SAD នៅពេលអនុវត្តចំពោះប្រតិវេទន៍គយនាំចេញ។ ប្រអប់និមួយៗត្រូវបានបរិយាយពីលំដាប់នៃការបញ្ចូលព័ត៌មាន ថាតើវាជាប្រអប់ចាំបាច់ ឬជាប្រអប់ជ្រើសរើស។ ប្រអប់ខ្លះ តម្រូវឱ្យបញ្ចូលលេខកូដយោង ឬ ឈ្មោះតំណាងអោយព័ត៌មានយោងតាមស្តង់ដារ។ កូដយោងដែលប្រើក្នុងកំណាត់ពន្យល់នេះនឹង ចេញដោយទីចាត់ការគយ និងរដ្ឋាករ។

**ការពន្យល់នៃប្រអប់ SAD សំរាប់ប្រភេទទន័នាំចេញ**

| លេខ ប្រអប់ | ផ្លាកសញ្ញា ប្រអប់ | សកម្មភាព | បរិយាយ និង / ឬ ការប្រើប្រាស់ |
|---|---|---|---|
| 1 | ប្រភេទប្រតិវេទន៍ | ចាំបាច់ | ដើម្បីកំណត់ថាតើប្រតិវេទន៍ទំនិញត្រូវបានដាក់សំរាប់ការនាំចូល ការនាំចេញ ឬ ក៏ជាការឆ្លងកាត់គយ។<br>លេខគំរូប្រតិវេទន៍ត្រូវបានដាក់បញ្ចូលលើទម្រង់ SAD ក្នុងប្រអប់នេះ។<br>សំរាប់ប្រតិវេទន៍នាំចេញទាំងអស់ គំរូនេះគឺ "EX" ជាមួយនឹងលេខដើម្បីកំណត់ថាតើរបបមួយណាជាការនាំចេញ ឧទាហរណ៍លេខ ១ សំរាប់ការនាំចេញ លេខ ២ សំរាប់ការនាំចេញបណ្តោះអាសន្ន ។ល។ |
| A: | ការិយាល័យដាក់ប្រតិវេទន៍: ការិយាល័យគយដែលប្រតិវេទន៍ត្រូវបានដាក់ជូនមន្ត្រីគយពិនិត្យ | | |
| | កូដការិយាល័យ | ចាំបាច់ | កូដនិងឈ្មោះការិយាល័យគយដែលប្រតិវេទន៍ (SAD) ត្រូវបានដាក់និងត្រូវបានដំណើរការ។<br>ការិរកាល័យគយដែល SAD ត្រូវបានដាក់អាចផ្សេងពីការិយាល័យគយដែលទំនិញត្រូវបាននាំចូល/នាំចេញពីប្រទេស (ប្រអប់លេខ២៩)។<br>ការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា នឹងបង្ហាញដោយស្វ័យប្រវត្តិនូវឈ្មោះការិយាល័យ បន្ទាប់ពីកូដត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធ។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទនករត្រូវបំពេញទាំងកូដការិយាល័យ និងឈ្មោះ ផ្អែកតាមបញ្ជីកូដយោង។ |

<table>
<tr><td></td><td>និវេទនប័ណ្ណ</td><td>ជម្រើស</td><td>នៅពេលបំពេញប្រតិវេទន៍នាំចេញ លេខនិវេទនប័ណ្ណត្រូវបានចុះចូលក្នុង SAD បើសិនជាមានព័ត៌មាន។</td></tr>
<tr><td></td><td>លេខ និងកាលបរិច្ឆេទបញ្ជិកាប្រតិវេទន៍គយ</td><td>ចាំបាច់</td><td>ការប្រើប្រាស់អាស៊ីគូដា នៅកន្លែងចុះបញ្ជិកា (ការទទួលយកតាមច្បាប់ដោយគយ នៅពេលដែលទំនិញបានមកដល់ និងនៅពេលដែលចាប់ផ្តើមបំពេញឯកសារ និងការដាក់បញ្ចូលទិន្នន័យត្រូវបានបំពេញ)។ ប្រព័ន្ធផ្តល់លេខចុះបញ្ជីឯកភាពដោយស្វ័យប្រវត្តិតែមួយផ្សំឡើងដោយលំដាប់អក្សរ + លេខ + កាលបរិច្ឆេទសំរាប់ការិយាល័យគយបច្ចុប្បន្ន និងឆ្នាំបច្ចុប្បន្ន។<br><br>ឧទាហរណ៍<br>
<table>
<tr><th>លំដាប់អក្សរ</th><th>លេខ</th><th>កាលបរិច្ឆេទ</th><th>ការិយាល័យគយ</th><th>ឆ្នាំបច្ចុប្បន្ន</th></tr>
<tr><td>E</td><td>32</td><td>15/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>E</td><td>33</td><td>20/11/2006</td><td>ក្រុងព្រះសីហនុ</td><td>2006</td></tr>
<tr><td>E</td><td>33</td><td>20/11/2006</td><td>អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ</td><td>2006</td></tr>
</table>
<br>ការប្រើប្រាស់ SAD ដោយដៃ គយជាអ្នកផ្តល់នូវលេខចុះបញ្ជីឯកភាព (ទម្រង់ដូចគ្នាទៅនឹងទម្រង់បានផ្តល់ដោយប្រព័ន្ធ) នៅ ពេលដាក់ប្រតិវេទន៍គយ SAD ។ គយត្រូវគ្រប់គ្រងប្រព័ន្ធចុះបញ្ជិកា ទៅក្នុងសៀវភៅចុះបញ្ជិកា / សៀវភៅចុះលេខប្រតិវេទន៍នៅថ្នាក់ការិយាល័យគយ និងផ្អែកលើមូលដ្ឋានប្រចាំឆ្នាំ។</td></tr>
<tr><td>2</td><td>កូដអ្នកនាំចេញ / អ្នកផ្ញើទំនិញ</td><td>ចាំបាច់</td><td>ចំពោះប្រតិវេទន៍នាំចេញ ជាទូទៅអ្នកនាំចេញគឺជាជនជាតិកម្ពុជា។ ជាធម្មតា គឺជាឈ្មោះនិងអាសយដ្ឋានបុគ្គល ឬ ក្រុមហ៊ុន ឬ ស្ថាប័ននៅក្នុងប្រទេស (កម្ពុជា) ដែលអ្នកនាំចេញទំនិញ ។<br><br>លោកអ្នកត្រូវបំពេញលេខ អ.ត.ប របស់អ្នកនាំចេញឬអ្នកផ្ញើទំនិញ ជាលេខកូដក្នុងប្រអប់ (សូមផ្តល់នូវឈ្មោះ និងអាសយដ្ឋានរបស់ បុគ្គលនោះនឹងបង្ហាញដោយស្វ័យប្រវត្តិ)។<br><br>ប្រសិន SAD ត្រូវបានបំពេញដោយដៃ ប្រតិវេទនករត្រូវបំពេញ ឈ្មោះ និងអាសយដ្ឋាន អ្នកនាំចេញ ផ្អែកតាមបញ្ជីកូដយោងដែលបានផ្តល់។<br><br>(លេខ អ.ត.ប. ត្រូវបានផ្តល់ឲ្យដោយនាយកដ្ឋានពន្ធដារ) ។<br><br><u>កំណត់សំគាល់:</u><br><br>អ្នកនាំចេញ/អ្នកផ្ញើទំនិញ ដែលគ្មានលេខ អ.ត.ប (អ្នកនាំចេញ/អ្នកផ្ញើទំនិញម្តងម្កាល) ត្រូវប្រើកូដ ៩៩៩៩៩៩៩៩៩៩ អ្នកនាំចេញ/អ្នកផ្ញើទំនិញម្តងម្កាល និងត្រូវបំពេញពេហ្មោះ ពេខអត្តសញ្ញាណប័ណ្ណ និង អាសយដ្ឋានក្នុងប្រអប់លេខ ៩ ។<br><br>ចំពោះអ្នកដែលកំពុងរង់ចាំលេខ អ.ត.ប របស់ខ្លួន ឯកសារពីនាយកដ្ឋាន</td></tr>
</table>

| | | | |
|---|---|---|---|
| | | | ពន្ធដារ (រាប់បញ្ចូលលេខ អ.ត.ប បណ្តោះអាសន្ន) ត្រូវតែបានភ្ជាប់ជាមួយ SAD។ |
| 3 | ទម្រង់ | ចាំបាច់ | ប្រអប់នេះបង្ហាញចំនួនសរុបនៃទំព័រក្នុងប្រតិវេទន៍ ដែលរាប់បញ្ចូលទាំងទំព័រមុខ និងទំព័របន្តណាមួយ (ទំព័របន្ថែម) មានន័យថា ២, ៣...។ល។ ទៅតាមត្រូវការ។<br>ដូចក្នុងឧទាហរណ៍ ប្រព័ន្ធអាស៊ីគូដានឹងបង្ហាញដោយស្វ័យប្រវត្តិ ប្រសិនបើប្រតិវេទន៍មាន៣ទំព័រ ១/៣ លើទំព័រទី១ ២/៣លើទំព័រទី ២ និង ៣/៣ លើទំព័រចុងក្រោយ ។<br>ការបញ្ចូលដោយដៃ នៃ SAD ត្រូវអនុវត្តតាមទម្រង់ដូចគ្នា។ |
| 4 | | មិនតម្រូវ | ចំនួនបញ្ជីផ្ទុកទំនិញឬឯកសារភ្ជាប់ប្រហាក់ប្រហែលផ្សេងទៀតភ្ជាប់ជាមួយការប្រកាសទំនិញ។<br>មិនទាន់ត្រូវការ នាពេលបច្ចុប្បន្ននេះទេ។ |
| 5 | មុខទំនិញ | ចាំបាច់ | ប្រអប់នេះបង្ហាញចំនួនមុខទំនិញសរុបក្នុងប្រតិវេទន៍។ ប្រតិវេទន៍នីមួយៗ អាចបំពេញមុខទំនិញបានជាអតិបរិមារហូតដល់ ៩៩មុខទំនិញ ។<br>ការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដា ចំនួនមុខទំនិញនឹងត្រូវបង្ហាញដោយស្វ័យប្រវត្តិ ។<br>ការប្រើប្រាស់ SAD ដោយដៃ ប្រតិវេទនករត្រូវបញ្ចូលក្នុងប្រអប់នេះ ។ |
| 6 | សរុបចំនួនភណ្ឌិកា | ចាំបាច់ | ការប្រើប្រាស់ SAD ដោយដៃ និងដោយអេឡិចត្រូនិក ប្រតិវេទន-ករ ត្រូវបង្ហាញនូវចំនួនសរុបភណ្ឌិកា សំរាប់ប្រតិវេទន៍ទាំងមូល (មានន័យថាចំនួនសរុបកញ្ចប់នៃមុខទំនិញទាំងអស់)។<br>ចំពោះទំនិញចាក់ធាលោកអ្នកអាចបញ្ចូលលេខ១ ។ |
| 7 | លេខយោង ប្រតិវេទនករ | ចាំបាច់ | នេះជាលេខលំដាប់ខាងក្នុង (មានន័យថាលេខប្រតិបត្តិការ) ដែលប្រតិវេទនករម្នាក់ៗ ត្រូវបំពេញលើ SAD (ដោយដៃ ឬដោយអេឡិកត្រូនិក)។<br>ប្រតិវេទនករ ត្រូវថែរក្សាផ្ទៃក្នុង "លេខប្រតិបត្តិការ" សៀវភៅចុះបញ្ជីរបស់ខ្លួន។ |
| 8 | អ្នកនាំចូល / អ្នកទទួលទំនិញ | ជម្រើស | ចំពោះប្រតិវេទន៍នាំចេញ អ្នកទទួលទំនិញជាទូទៅជាអ្នកនាំចូលនៅក្រៅប្រទេស ។ អ្នកទទួលទំនិញ គឺជាបុគ្គល ឬ ក្រុមហ៊ុន ឬ អង្គការ ដែលទំនិញត្រូវបានគេផ្ញើរអោយ។ ជាទូទៅឈ្មោះរបស់បុគ្គល ឬអង្គការនៅឯក្រៅប្រទេស ដែលអ្នកនាំចេញនៅកម្ពុជាផ្តល់ឲ្យ។<br>ចំពោះប្រតិវេទន៍នាំចេញ ប្រអប់នេះជាជម្រើស។ ប្រសិនបើមានព័ត៌មាន សូមបំពេញនូវឈ្មោះ និងអាសយដ្ឋាន រួមទាំងអាសយដ្ឋានអ៊ីមែលផង (ប្រសិនបើមាន) របស់អ្នកនាំចូល/អ្នកទទួលទំនិញ ពីកម្ពុជា។ |
| 9 | អ្នកទទួលទំនិញ /អ្នក | ជម្រើស | ប្រអប់នេះត្រូវបានបំពេញ វាលែងតែជាអ្នកនាំចេញមានលក្ខណៈម្តង |

| | | | |
|---|---|---|---|
| | នាំចេញ | | ម្តាលប៉ុណ្ណោះ ។ ក្នុងករណីនេះ ត្រូវបំពេញឈ្មោះអ្នកនាំចេញ អត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋានក្នុងប្រអប់រងរបស់អ្នកនាំចេញម្តងម្តាល។<br><br>អ្នកនាំចេញម្តងម្តាល គឺជាបុគ្គល ឬ ក្រុមហ៊ុន ដែលធ្វើការនាំចេញតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីនេះក្រុមហ៊ុននឹងមិនមានលេខ អ.ត.ប ទេ ។ ប្រសិនបើក្រុមហ៊ុនមានបំណងក្លាយជាអ្នកនាំចេញទៀងទាត់ នោះក្រុមហ៊ុនត្រូវមានលេខ អ.ត.ប ។ |
| 10 | ប្រទេសមក/ទៅដល់ | ជម្រើស | នេះជាកូដប្រទេស ដែលទំនិញត្រូវបានផ្ទេរពីមធ្យោបាយដឹកជញ្ជូនសម្រាប់ធ្វើការនាំចេញ។ |
| 11 | | មិនតម្រូវ | នេះគឺជាប្រទេសដែល សហ-សហគ្រិនម៉ៅការនៃអ្នកនាំចេញ ត្រូវបានតាំងលំនៅ ឬមានរបរជំនួញរបស់ខ្លួន។<br><br>មិនទាន់ត្រូវការ សំរាប់ពេលបច្ចុប្បន្ននេះទេ។ |
| 12 | តម្លៃលំអិត | ចាំបាច់ | ប្រអប់នេះមានចន្លោះដើម្បីបញ្ចូលលំអិតនូវកម្រៃផ្សេងៗ (មិនត្រូវបានដាក់បញ្ចូលទៅក្នុងវិក្កយបត្រ) ដែលទាក់ទងទៅនឹងការគណនាតម្លៃគិតពន្ធគយនៃទំនិញ ។<br><br>ការពន្យល់:<br><br>ប្រសិនបើ មានការលក់រវាងអ្នកលក់និងអ្នកទិញ ហើយថ្លៃលើវិក្កយបត្រគឺមិនក្នុងកម្រិត FOB បន្ទាប់មកការចំណាយផ្សេងៗ ត្រូវបានបូកបន្ថែមទៅលើតម្លៃ EXW ។ ការចំណាយ និងសោហ៊ុយផ្សេងៗ អាចជាសោហ៊ុយដឹកជញ្ជូនក្នុងប្រទេសការធានាភ័ប់រង សោហ៊ុយដឹកជញ្ជូនផ្សេងៗ ឬ សោហ៊ុយលើកដាក់ សោហ៊ុយពីទំនិញក្នុងស្រុក ។ល។ និង ត្រូវបូកបន្ថែមទៅក្នុងតម្លៃទំនិញនៅ"កន្លែង" ឬ "កម្រិត" ត្រឹមត្រូវ។<br><br>ប្រសិនបើប្រព័ន្ធអាស៊ីគូដាត្រូវបានប្រើ ប្រអប់តម្លៃលំអិតនេះ នឹងបង្ហាញដោយស្វ័យប្រវត្តិដោយប្រព័ន្ធ ។<br><br>ប្រសិនបើ SAD ត្រូវបានប្រើប្រាស់ដោយដៃ ប្រតិវេទនករត្រូវបញ្ចូលចំនួនទឹកប្រាក់នៃ "កម្រៃផ្សេងៗ" ។<br><br>កំណែតម្រូវសរុបចំពោះថ្លៃវិក្កយបត្រ ត្រូវបានបន្ថែមតាមសមាមាត្រទៅតាមមុខទំនិញដែលបានប្រកាស ក្នុងករណីដែលប្រតិវេទន៍មានច្រើនជាងមួយមុខទំនិញ ។ |
| 13 | អ.ទ.ម.ផ. | ចាំបាច់ | ប្រអប់នេះត្រូវបានប្រើសម្រាប់ទំនិញឆ្លងយន្តការ PSI<br><br>ឧទា: លេខ០=មិនជាប់PSI, លេខ១=ឆ្លងPSI, លេខ២=មិនឆ្លងPSI<br><br>សម្រាប់ប្រតិវេទន៍នាំចេញប្រអប់នេះត្រូវបំពេញ (0) |
